«មានរឿងតំណាលថា កាលពីមុនរាជវាំងនេះត្រូវបានសាងសង់ឡើងនៅក្នុងសម័យកាលដ៏រុងរឿងបំផុតមួយរបស់ព្រះចៅអធិរាជនៃរាជវង្សហ្ស៊ូដា ដែលបានកាន់កាប់អំណាចអស់រយៈពេល៩ជំនាន់ចំនួនដែលសុទ្ធសឹងតែជាអធិរាជកំពូលសង្គ្រាម ទោះបីយ៉ាងណានៅក្នុងរាជវាំងខាងក្រោយរបស់អធិរាជគ្រប់អង្គ តែងតែមានបន្សល់ទុកនូវព្រេងនិទានស្នេហ៍ដ៏កម្សត់កម្រ និងផ្អែមល្ហែមជាមួយស្រីស្នំជាច្រើន រាប់ចាប់តាំងពីព្រះនាង កូនមន្ត្រីធំ គហបតី រហូតដល់គោលដៅរាស្ត្រសាមញ្ញជាច្រើន! នៅក្នុងចំណោមនោះ មានរឿងនិទានថា ស្នំថ្នាក់ទាបម្នាក់ឈ្មោះនាងប៊ុនលីវ៉ាវី មានប្រវត្តិស្នេហាល្អកល្អិនកម្សត់ជាងគេ ជាមួយព្រះចៅអធិរាជនៃជំនាន់ទីបីក្នុងរាជវង្សហ្ស៊ូដា ឈ្មោះថាព្រះចៅ អង្គមែនរ៉េត៍។ ព្រះចៅអង្គបានទតឃើញនាងនៅខណៈពេលមួយ ទើបនឹងយាងត្រឡប់មកពីសមរភូមិ។ នាងជាមនុស្សស្រីកំព្រារស់នៅនឹងម្ដាយមីងត្រូវគេប្រើឱ្យត្បាញតាំងពីយប់ទប់ព្រឹកឡើងៗ មិនហើយមិនឱ្យសម្រាក!»

«ចុះតើស្ដេចនឹងស្នំនោះបានជួបគ្នាជាគូដែរទេ»

សំឡេងស្រួយស្រែះ នារីម្នាក់ភ្លាត់មាត់សួរឡើងកាត់សម្ដីពូជាមគ្គុទេសក៍ដែលកំពុងនិយាយរៀបរាប់ប្រាប់អំពីរាជាវាំងមួយនេះ និងប្រវត្តិស្នេហាកាលពីជំនាន់យូរលង់។

គ្រប់គ្នាងាកមកសម្លឹងនាង។ នាងមានមាឌតូចល្អិតបានជាពីមុនមកគ្មាននរណាដឹងថាក្នុងចំណោមនិស្សិតបុរាណវិទ្យាដែលកំពុងតែមកស្ដាប់អ្នកនាំផ្លូវ លើកឡើងអំពីប្រវត្តិស្នេហាចាស់នៃរាជវាំងនេះ មានម្នាក់រូបស្អាតភ្លេចចាប់អារម្មណ៍។

ឃើញគេមើលមកគ្រប់គ្នា មាណវីយើងហាក់បីដូចជាមានអារម្មណ៍អៀនខ្មាសដែរ នាងខាំបបូរមាត់ខាងក្រោមតិចៗ រួចទើបញញឹមហើយភ្នែកក៏រេទៅឆ្វេងស្ដាំយឺតៗ។

ប្រុសពិតជាកំពុងងាកសម្លឹងមើលមកគ្រប់គ្នាដោយអារម្មណ៍ភ្ញាក់ផ្អើល ចំពោះមនុស្សស្រីតូចល្អិតសក់វែងដល់ចង្កេះខ្មៅ កែវភ្នែកធំៗមុតៗច្រមុះស្រួចដូចជាកូនតណ្ហា បបូរមាត់មានរូបរាងជាបេះដូងទៀត។

បបូរមាត់នេះអៀនផង ខាំផងញញឹមស្វាគមន៍ទៅកាន់គ្រប់គ្នា ដូចជាធ្វើឲ្យវត្តមានអ្នកមគ្គុទេសក៍នាំផ្លូវលែងសំខាន់ ចំណែករឿងនិទានចាស់ក៏ផុតរលត់ទៅបាត់។

ក្រុមនេះ ឃើញម្នាក់ៗដូចជាពន្យារពេលវេលាក្នុងការសម្លឹងមកស្រីស្អាត ដោយសារក្នុងចំណោមអ្នកស្ដាប់ទាំងអស់ភាគច្រើនជាបុរស រីឯមនុស្សស្រីមានតែពីរបីនាក់ហើយសុទ្ធតែមានវ័យច្រើន។

មានតែនាងម្នាក់ដែលនៅក្មេងជាស្រីក្រមុំផង។

អស់អ្វីធ្វើ តរុណីរបស់យើងក៏លើកដៃជាសញ្ញាហើយនិយាយថា៖

«ខ្ញុំឈ្មោះមេរូ!»

មេរូ មានន័យថាស្រស់បំព្រងនៅក្នុងភាសារបស់នេប៉ាល់។ មេរូនេះឯងគឺជានិស្សិតបុរាណវិទ្យា អាចចុះកម្មសិក្សាជាញឹកញាប់ ព្រោះថានាងចូលចិត្តខ្លាំង។ នាងមានទម្លាប់នៅក្នុងការលូកមាត់សួរនាំច្រើន ទាក់ទងជាមួយនឹងរឿងបុរាណគ្រប់ពេល នៅពេលដែលអ្នកនាំផ្លូវឬក៏មគ្គុទេសក៍ទេសចរណ៍និយាយរៀបរាប់ម្ដងៗ នាងតែងតែស្លុងជ្រៅ និងមិនអស់ចិត្តមិនអស់មិនហើយត្រូវតែជជីកសួរ។

មិននឹកស្មានថា ពេលនេះការចុះលើកនេះមិនមែនជាក្រុមរបស់ថ្នាក់នាងផង ប៉ុន្តែនាងសុំទៅជាមួយក្រុមបងជីដូនមួយ នាងបែរជាត្រូវបានធ្វើឲ្យគ្រប់គ្នាអាក់ខាននៅកណ្ដាលទីបានទៀត។

អ្វីៗដូចគាំង មេរូបើកភ្នែកធំៗ សួរទៀតដោយញញឹមហើយរៀងអៀនៗដោយសារថាអត់មានអ្នកណានិយាយបន្តទៀតសោះ។

«ខ្ញុំចង់ដឹងថាតើអធិរាជបានជួបនារីម្នាក់នោះដែរឬអត់ ពួកគេបានជួបគ្នាជាស្វាមីភរិយាដែរ?»

មគ្គុទេសក៍ឆ្លើយតបវិញ ៖

«នេះគឺជារូបដែលឆ្លាក់មកដោយវិចិត្រករឥណ្ឌាដ៏ល្បីម្នាក់ មានទាំងកំណាព្យជាអក្សរភាសាឥណ្ឌា ដោយលើកឡើងពីស្នេហារបស់ទ្រង់និងនាងប៊ុនលីវ៉ារី ថាក្រោយមកអ្នកទាំងពីរបានក្លាយទៅជាអ្នកសោយរាជ្យជាមួយគ្នាដោយសេចក្ដីស្នេហាអមតៈ ប៉ុន្តែរឿងដែលមិនអស់ចិត្តនោះ គឺថាព្រះរាជាស្រាប់តែសោយទិវង្គតចោលក្សត្រីប៊ុនលីវ៉ារីកណ្ដាលផ្លូវ»

«អូ អត់ទេ! ហេតុអីក៏កម្សត់បែបនោះ? ហើយរឿងតែទៅមុខទៀតយ៉ាងម៉េច?» នាងសួរដោយក្រឡង់ដូចមិនអស់ចិត្តខ្លាំង។

សាជាថ្មីគ្រប់គ្នាបែរមកកាន់នាង ប៉ុន្តែនាងរកញញឹមមិនរួចទៀតនោះទេ។ មេរូដូចអន្ទះសាលើកដៃឲ្យសញ្ញាទៅអ្នកមគ្គុទេសក៍ឲ្យនិយាយបន្តថាយ៉ាងណាទៀត។ អ្នកមគ្គុទេសក៍ចាប់ផ្ដើមចង្អុលទៅកាច់ជ្រុងម្ខាង។

«នៅនោះមានពូម្នាក់ គាត់មានលក់សៀវភៅរឿងបុរាណដែលរៀបរាប់អំពីស្នេហាស្អិតល្មួតរបស់នារីប៊ុនលីវ៉ារី និងអធិរាជកាលពីសម័យនោះ! ពូថារាជវាំងនេះបានចាប់ផ្ដើមចុះចាញ់ ហើយក៏រលាយទៅ នៅក្រោយពេលដែលអធិរាជលែងមានវត្តមាន!»

«ហេតុអីបានជាអធិរាជស្លាប់?»

«ប្រាប់ថាឲ្យទិញសៀវភៅអានទៅ!»

«ខ្ញុំគ្រាន់តែសួរថា ចុងក្រោយម៉េច? សៀវភៅគង់តែទិញទេ!»

«ពូសួរថាពួកគេក្រោយមកក៏អន់ចិត្តគ្នារវាងស្នំប៊ុនលីវ៉ារីនិងព្រះរាជានោះ ព្រោះអធិរាជសង្ស័យប៊ុនលីវ៉ារីមានទំនាក់ទំនងជាមួយនឹងប្រុសកំលោះម្នាក់ធ្លាប់នៅភូមិជាមួយគ្នា ហើយទីបំផុតទៅប្រុសកំលោះនោះបានចូលមករកនាងដែលបន្លំខ្លួនជាទាហាននៅក្នុងវាំង! ព្រះចៅអធិរាជពិតជាមានកំហឹងជាខ្លាំង ហើយក៏បានបញ្ជាឱ្យយកប្រុសនោះចុះទៅឃុំបម្រុងប្រហារជីវិតព្រឹកស្អែក ក៏មិនដឹងដែរថាមូលហេតុអ្វី យប់ដដែលនោះទ្រង់ត្រូវបានគេឃើញលង់ទឹកស្លាប់នៅក្នុងអាងទឹក ផ្ទាល់ខ្លួននាប្រាសាទហិណ្ឌូ ដែលមានតែអធិរាជនិងរាជនីដែលទេអាចក្រសាលស្រង់បាន!»

«Interested»

នាងភ្លាត់មាត់ជាភាសាអង់គ្លេសជាមួយទឹកមុខអណោចអាធម៌អាណិតស្ដេច ធ្វើឲ្យគ្រប់គ្នាសើចគឹលឡើង។ មនុស្សម្នាក់នៅក្នុងចំណោមនោះ រេខ្លួនឱនមកខ្ចឹឱ្យនាងដោយនិយាយថា៖

«មនុស្សស្រីពិសពុលខ្លាំងណាស់!»

មេរូបែរមកភ្លាមហើយព្រមានគេតែម្ដង៖

«ប្រយ័ត្នសម្ដីបន្តិច!»

ថាឱ្យម្នាក់នោះហើយកាលណាមេរូបន្តធ្វើមុខមាំ។

ម្នាក់នោះនាងស្គាល់ច្បាស់ ថាគេនោះហើយជាមនុស្សដែលតាមសម្លឹងមកនាងតាំងពីខាងក្រៅប្រាសាទនេះរហូតដល់ខាងក្នុង មិនចង់ដឹងថាគេឈ្មោះអ្វីនោះទេ។

ចំណែកបងប្រុសជីដូនមួយនាងនៅពីក្រោយខ្នងនាង ដោយលើកដៃគោះស្មាឱ្យមេរូទប់ចិត្តកុំយកកំហឹងទល់កំហល់។

មេរូងាកមកខ្សឹបពន្យល់បងប្រុស៖

«ព្រោះខ្ញុំមិនបាននិយាយអីមិនល្អឯណា! ហើយម៉េចក៏គេចាំបាច់ឲ្យចេញចរិតមកវាយតម្លៃមើលងាយមនុស្សស្រី!»

«គ្មាននរណាមើលងាយខ្លួនទេ!»

ម្នាក់ដដែលបន្ដមកទៀត ហើយពួកគេនាំគ្នាសើចគឹលឡើងសាជាថ្មីជាដដែល។ ដោយសារបងជីដូនមួយនាង ចាប់ផ្ដើមហាមឃាត់អត់បានហើយ ក៏ឈប់និយាយទុកឱ្យពូមគ្គុទេសក៏ចេញមុខស្ដីឱ្យប្រុសៗម្ដងវិញថា៖

«នៅទីនេះជាកន្លែងស័ក្តិសិទ្ធិ កុំនាំគ្នាលេងសើចច្រើន!»

ពូនោះនិយាយប្រាប់គ្រប់គ្នាទៀតថាឱ្យតមមាត់តមសំដីបន្តិចហើយបបួលគ្រប់គ្នាឡើងថា៖

«តស់យើងទៅអុជទៀនអុជធូប នេះជាទម្លាប់នៅប្រាសាទនេះ គឺគេតែងតែត្រូវអុជទៀនមួយគូ គេមានជំនឿថា ជារៀងរាល់យប់អធិរាជនិងភរិយាតែងតែអុជទៀនអានសៀវភៅ និងតែងកំណាព្យ ច្រៀងលេងជាមួយគ្នា សំខាន់កាលនៅក្មេងរាជនីតែងទទួលទណ្ឌកម្មដេរប៉ាក់មួយយប់ទល់ភ្លឺ ភ្លើងទៀនគឺសំខាន់ណាស់សម្រាប់ទ្រង់»

«ខ្ញុំចង់ទិញសៀវភៅនេះច្បាស់ណាស់!»

មេរូខ្សឹបទៅបងប្រុសឈ្មោះមីន តែមីនបើកក្រញាំខោកក្បាលនាងតិចៗប្រាប់វិញដោយធ្វើភ្នែកក្រឡេកក្រឡាប់ ៖

«ហើយឯងក៏ចាញ់ឃោសនារបស់គេដែរអាមេរូ? ជឿថា ជាការធ្វើទីផ្សាររបស់គេទេ?»

«ប៉ុន្តែនារីនោះកម្សត់ណាស់បងមីនឯងមិនឃើញទេ!»

«នៅឯណាបងមិនឃើញទេ!»

«គឺក្នុងរឿងនិទាន!»

បងមេរូហួសចិត្តដើរហួទៅចោលនាង នាងរត់តាមពន្យល់ទៀត៖

«ដើមឡើយនាងគួរតែជាមនុស្សចិត្តល្អហេតុអីបានជាសម្លាប់ប្ដីខ្លួនឯង?»

«មាននរណាថានារីនោះសម្លាប់ប្ដី?» មីនសួរប្អូនទាំងទឹកមុខបង្ហាញថាធុញ។

«ដូច្នេះ....គឺ  អ៊ីចឹងហើយ....គឺ...ម្នាក់នោះ! អឺចុះមិញម៉េចគេនិយាយថា មនុស្សស្រីពិសពុល ខ្លាំងណាស់នោះ?»

មីនបន្ទោសវិញ៖

«ឯងកុំយកមកដាក់ខ្លួនខ្លាំងពេក! រៀនមានទំនុកចិត្តខ្លះនិងដាក់ចិត្តខ្លះទៅ! តិចបងលែងនាំមក!»

«ថ្ងៃក្រោយកុំឲ្យខ្ញុំឃើញម្នាក់ហ្នឹងទៀតឲ្យសោះ!»

នាងដើរមកដល់កន្លែងលក់ល្ខោម។

«ពូអ្នកលក់! មានរឿងប្រវត្តិអធិរាជនិងនារីតម្បាញទេ?!»

«អូលក់អស់ហើយគ្មានសល់ទេ! ភាសាអង់គ្លេសក៏អស់ហិណ្ឌូក៏អស់! ភាសានេប៉ាល់ក៏មិនសល់ដែរ! »

«ហេតុអីបានជាមិនសល់?!»

«មិនសល់គឺលក់អស់ហ្នឹងណ៎ា!»

មេរូងាកមកទាំងខឹងព្រោះនាងស្គាល់សំលេងច្បាស់ គឺម្នាក់ដដែលហ្នឹងឯងជាអ្នកឌឺដងនាង ។ គាប់ចួនដៃគេបានកាន់សៀវភៅមួយបង្ហាញមកទៀត ច្បាស់ហើយគេនេះជាអ្នកទិញបង្អើយបានមុននាង។

បងជីដូនមួយនាង គឺមីនបានទាញដៃមេរូឲ្យដើរទៅមុខ។ តែនាងនៅបន្តរអ៊ូទាំងក្រញូវៗ៖

«ខ្ញុំប្រាប់ហើយថាមិនមែនគេធ្វើទីផ្សារទេ! អន់ខ្លាំងណាស់ថ្ងៃនេះ!»

យប់នោះត្រឡប់មកផ្ទះវិញ មេរូនឹកឃើញតែរឿងរបស់អតីតរាជវាំង។ ស្រាប់តែឃើញសំបុត្រមួយទុកនៅលើតុបាយ។

«គ្នាទៅផ្ទះនៅស្រុក! ប្រហែលជាឯងត្រូវគេងម្នាក់ឯងពីរបីយប់ហើយ ម៉ាក់គ្នាឈឺ! បើថានេះឯងហៅបងមីនមកកំដរទៅប្រសិនខ្លាច!»

មេរូបើកកាបូបរុករកទូរសព្ទ រួចទើបចុចប្រញិបប្រញាប់។

«ហេ មេនសា តែម្ដាយរបស់ឯងគាត់ឈឺអ្វីទៅ!»

«ខ្ញុំមិនដឹងទេ អ្នកស្រុកថានៅផ្ទះមានព្យុះហើយគ្មានអ្នកណាម្នាក់អាចមើលថែនរណាម្នាក់ទេ នៅពេលដែលខ្យល់កំពុងតែសម្រុកខ្លាំង! ក្រោយខ្យល់ស្ងប់ទៅពួកគេបានឃើញគាត់នៅមុខផ្ទះ ដួលដេកម្នាក់ឯង!»

«ស្ថានភាពមីងយ៉ាងម៉េចដែរ? ឯងគួរតែនៅចាំខ្ញុំបន្តិច ខ្ញុំអាចកំដរឯងទៅស្រុក!»

«ទៅកុំខ្វល់ពីរឿងខ្ញុំ មេរូឯងនៅសល់Assignment ច្រើន នៅចុះ ហើយកុំភ្លេច ហៅបងមីនមក កំដរទៅ!»

មេរូឆ្លើយឡើង៖

«គិតពីរឿងរបស់អ្នកមីងទៅ! បើឯងចាំតែបន្តិចខ្ញុំនឹងទៅជាមួយមិនខាន មិនអីទេប្រហែលស្អែក អីខ្ញុំរកពេលបានជិះឡានក្រុងទៅភ្លាម!»

«មិនបាច់ទៅទេ ស្រីនោះមិនរស់នោះទេ!»

នេះមិនមែនសំឡេងអ្នកណាដែលនាងស្គាល់ទេ មិនមែនមេនសាឬមេរូទាំងអស់។ សំឡេងម្យ៉ាងជាសំឡេងមនុស្សប្រុសលាន់មកក្នុងបេះដូងរបស់នាង ធ្វើឲ្យមេរូភ្ញាក់សឹងរបូតដៃធ្លាក់បែកទូរសព្ទហើយ។

មេរូបែរក្រោយយឺតៗមើលជុំវិញខ្លួន។

តើមិញនេះជាសំឡេងអ្វី?

គេចង់សំដៅអ្នកណា?

មេរូ ឈរសម្លឹងជុំវិញខ្លួនហើយឮតែ អាឡូ...អាឡូ សំឡេងរបស់មិត្តភក្តិ។

បានមេនសាហៅដាស់អារម្មណ៍មេរូត្រឡប់មកវិញ នាងពិតជានៅតែងឿងឆ្ងល់ថាអ្នកណានិយាយពាក្យដែលគួរឲ្យខ្លាចមុននេះ តែនាងគ្មានចម្លើយសម្រាប់ខ្លួនឯងទេ។

ភ្លាមនោះ មេនសាក៏បាននិយាយបន្ថែម៖

«អូខេប៉ុណ្ណឹងចុះណាខ្ញុំទៅហើយ ឯងមិនបាច់ពិបាកចិត្តទេ! ខ្ញុំដល់កន្លែងចុះហើយ!»

«យ៉ាងម៉េចក្តីឯងក៏ត្រូវតែឲ្យដំណឹងមកខ្ញុំ! ត្រូវការអី ក៏ឆាប់ប្រាប់ណា!»

«ខ្ញុំថាខ្ញុំមិនអីទេគេងទៅ!»

ថាហើយមិត្តនាងក៏បិទទូរសព្ទ។ មេរូចូលងូតទឹក ហើយឈរសញ្ជឹងគិតម្នាក់ឯង ដោយធ្មេចភ្នែកទទួលយកតំណក់ជលធាត្រជាក់ស្រេង។

ចិត្តនាងបានអធិដ្ឋានថា ព្រះម៉ែទេវី សុំតាមថែរក្សាពួកយើង! សុំឲ្យម្ដាយរបស់មេនសាគេចផុតពីគ្រោះថ្នាក់!

នរណាម្នាក់បង្ហាញខ្លួននៅក្រោយខ្នងរបស់នាង។

មេរូភ្ញាក់ព្រើតសឹងតែរបូតដបសាប៊ូដែលនាងកំពុងតែកាន់។ នាងមិនយល់ទេថា ម្ដេចបានធ្មេចភ្នែកនៅឡើយបែរជាដឹងបានពីមនុស្សរត់កាត់ក្រោយខ្នង។

ទោះបីចង់មិនចង់មេរូ បានសម្រេចចិត្តទាញកន្សែងគ្របខ្លួនហើយងាកក្រោយយឺតៗ។

ភ្លាមគ្មាននរណានៅទីនេះទេ មានតែបង្អួចនិងខ្យល់បក់បោកវាំងននរេរាំ។ ប្រហែលជាដោយសារមេនសា ចាកចេញប្រញិបប្រញាប់ពេក បានជាភ្លេចភ្លាំងរហូតដល់ថ្នាក់មិនបិទវា។